ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលសាលាខេត្តពោធិ៍សាត់

លេខ:០០៧/១៧ ..ខេ.ព.ស

ពោធិ៍សាត់.ថ្ងៃទី០៤..ខែ.កក្កដា...ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង

## ស្តីពី ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

យោងតាមអនុក្រឹត្យលេខ៤៦អនក្រ.បកចុះថ្ងៃទី៣១ខែឧសភា ឆ្នាំ២០០២ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី រដ្ឋបាលខេត្តពោធិ៍សាត់ សូមជូនដំណឹងដល់សាធារណៈជន ព្រមទាំងគ្រប់មន្ទីរ អង្គភាព និងគ្រប់ស្ថាប័ន ឬ ភ្នាក់ងារហិរញ្ញវត្ថុដែលមានការពាក់ព័ន្ធ និងក្បាលដីទាំងអស់ ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យក្នុង ភូមិចំរេះ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ អោយបានជ្រាបថា:

ដើម្បីអនុវត្តតាមខ្លឹមសារ នៃអនុក្រឹត្យខាងលើគណៈកម្មការរដ្ឋបាល និងធ្វើការបិទផ្សាយជាសាធារណៈ នូវឯកសារសុរិយោដី រួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ដែលក្រុមប្រតិបត្តិកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីបានធ្វើការវាស់វែង និងប្រមូលទិន្នន័យកន្លងមក ។

សេចក្តីដូចបានជម្រាបជូន ខាងលើសូមសាធារណៈជន និងអង្គភាពនានាដែលមានការពាក់ព័ន្ធ នឹងដីធ្លីស្ថិតនៅក្នុងតំបន់វិនិច្ឆ័យខាងលើមេត្តាចូលរួមពិនិត្យលើទិន្នន័យដែលមាននៅក្នុងឯកសារនៃការវិនិច្ឆ័យ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ខុសឆ្គងដែលត្រូវកែតម្រូវ ឬ ជំទាស់លើទិន្នន័យទាំងនោះ ក្នុងរយៈពេល ១៥ថ្ងៃ (រាប់បញ្ចូលទាំងថ្ងៃឈប់សំរាក) គិតចាប់ ពីថ្ងៃទី.១៤...ខែ.កក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៨...ខែ.កក្កដា ឆ្នាំ២០១៧ ជាកំហិត នៅក្នុងបរិវេណស្នាក់ការភូមិ ស្ថិតនៅ ភូមិចំរេះ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

ផុតកំណត់ខាងលើនេះគណៈកម្មការរដ្ឋបាលសន្មតថាទិន្នន័យដែលបានបើកចំហរ ជូនពិនិត្យជាសាធារណៈនេះ មានភាពត្រឹមត្រូវ ហើយមិនអាចជំទាស់ ឬ តវ៉ានៅពេលក្រោយទៀតបានឡើយ ។

<u>សេចក្តីបញ្ជាក់:</u> ផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនេះគណៈកម្មការរដ្ឋបាល និងប្តូកសរុបលើកសំណើផ្តល់សិទ្ធិលើអចលនវត្ថុទៅ **អភិបាលនៃគណៈអភិបាលខេត្ត** ដើម្បីសម្រេចរួចបញ្ជូនទៅរដ្ឋបាលសុរិយោដីចេញនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនអ្នកកាន់កាប់ណាដែលបានបំពេញគ្រប់លក្ខណៈតាមច្បាប់ ។

គណៈកម្មការរដ្ឋបាលនឹងដាក់ទីតាំងបណ្តោះអាសន្ននៅកន្លែងបិទផ្សាយដើម្បីចាំទទួលពិគ្រោះ និងផ្តល់យោបល់ដល់អ្នកដែលមានសំណូមពរ ។/.

**អភិបាលខេត្ត**

ម៉ៅ ធនិន

<u>ចម្លងជូន:</u>

- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP)
- គណៈកម្មការរដ្ឋបាល

  (ដើម្បីជូនជ្រាបជាពត៌មាន)
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់
- សាលាស្រុកកណ្តៀង
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកកណ្តៀង
- សាលាឃុំស្រែស្តុក
- គ្រប់ធនាគារ និងអង្គភាពហិរញ្ញវត្ថុ

  (ដើម្បីជ្រាបជាពត៌មាន និង ជួយផ្សព្វផ្សាយ)
- ឯកសារ-កាលប្បវត្តិ